អេម៉ាន្ទូអែល

សំលេងពីព្រះសហគមន៍កាតូលិក

FM: 91 Mhz ខេត្តបាត់ដំបង

៧:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 88 Mhz ខេត្តកំពង់ធំ

១២:៣០- ១:៣០ នាទី រៀងរាល់ល្ងាចថ្ងៃសៅរ៍

FM: 102.5 Mhz ខេត្តសៀមរាប

១០:០០-១១:០០ នាទី រៀងរាល់ថ្ងៃសៅរ៍

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍ កាតូលិក រតនះ

- *បំលែងឯកសារពី VHS ទៅ DVD ទៅ VCD*
- *បំលែងចំរៀងពី កាសែតចម្រៀង ទៅ CD*
- *បង្កើតឯកសារវីឌីអូ សំរាប់ លោកឌ៍ពុក បងស្រី បងប្រុស។*

ទំនាក់ទំនង ០៩២ ៦០៩ ៨៦៨

ព័ត៌មានប្រចាំខែ ភូមិភាគ បាត់ដំបង

- ថ្ងៃទី៦ កុម្ភះ : ព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំពិធីអុជធូប និងកាន់ទុក្ខ ដែលមានរយៈពេលប្រាំពីរថ្ងៃ ជូនចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះបាទនរោត្តម សីហនុ ។ ពិធីបុណ្យប្រារព្ធឡើងក្នុងបំណងរំលឹក ដល់ដួងវិញ្ញាណក្ខខ្ធរបស់ព្រះអង្គ និងការចូលរួមសម្តែងនូវការកាន់ទុក្ខ ដែលមានរយៈពេលប្រាំពីរថ្ងៃ។ ពិធីនេះធ្វើឡើងស្រប ពេលពិធីអភិបូជា ដែលមានការចូលរួម និងថ្វាយអភិបូជាដោយលោក អភិបាល គីគេ និងលោកបូជាចារ្យ បីអង្គ ព្រមទាំងមានការចូលរួមពីបងប្អូនគ្រីស្តបរិស័ទយ៉ាងច្រើនទៀតផង។ នៅក្នុងពិធីរំលឹកនេះផងដែរ ក៏មានក្បួនដង្ហែររូបព្រះធាយាល័ក្ខ ឆ្ពោះទៅព្រះវិហារ ថ្វាយអភិបូជាផងដែរ។

ល្បែងកំសាន្ត

ចូលរកជចំណុច ដែលខុសគ្នានៃរូបភាពទាំងពីរ





Apostolic Prefecture of Battambang Monthly News. For Internal Circulation

រតនះ

RATTANAK

មហាគ្រួសារព្រះសហគមន៍ កាតូលិក

Our Family

ព័ត៌មានព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ប្រចាំខែ កុម្ភះ ឆ្នាំ ២០១៣ លេខ ៤៧



ពិធីទទួលជំហានទី២

មាតិកា

- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តព្យាបាលធ្មេញ មកពីប្រទេស កាណាដា ទំព័រ ២
- សិក្ខាសាលា អន្តរជំនឿ និងការរួមគ្លាការពារបរិស្ថាន ទំព័រ ៦
- សិក្ខាសាលាភាពជាអ្នកណែនាំ ទំព័រ ៤-៥

ទំព័រ ៣

ក្រុមគ្រូពេទ្យស្ម័គ្រចិត្តព្យាបាលធ្មេញ មកពីប្រទេស កាណាដា

Photo: Moy Samet

ដោយៈមុយ សាម៉ែត

សុខភាពមាត់ធ្មេញពិតជាមានសារៈសំខាន់ណាស់ដល់មនុស្សគ្រប់រូប ហើយអ្វីជាពិសេសជាងនេះទៅទៀតនោះ គឺយើងម្នាក់ៗត្រូវយកចិត្តទុកដាក់ក្នុងការថែទាំឲ្យបានល្អ។

នៅព្រះសហគមន៍ កាតូលិកបាត់ដំបង កាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១៣ មានក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដែលមកពីប្រទេស កាណាដា បានធ្វើការព្យាបាល ជូនបងប្អូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ។ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដែលមានឈ្មោះថា ខាយនីស អ៊ីន អាក់ស៊ិន (Kindess in Action) ដែលមានគ្រូពេទ្យ ២០នាក់ បានធ្វើការព្យាបាលដូចជា ដក ប៉ះ និងសំអាត។ ក្នុងនោះពួកគាត់ បានព្យាបាលនៅតាមព្រះសហគមន៍នានាដូចជា ព្រះសហគមន៍ តាហែន ចំណោមស្វាយស៊ីសុផុន និងព្រះសហគមន៍កាតូលិកបាត់ដំបង។ គោលបំណងដែលពួកគាត់មកទីនេះ គឺដើម្បីជួយដល់បងប្អូន ក្រីក្រ ដែលគ្មានលិទ្ធភាពចំណាយថវិកាច្រើន ទៅលើការព្យាបាលនៅខាងក្រៅ និងដើម្បីមានទំនាក់ទំនងល្អ រវាងប្រជាជនខ្មែរ និងក្រុមរបស់ពួកគេ។ ស្របពេលនោះដែរ លោក ស៊ឹង ញាន អាយុ ២២ឆ្នាំ ដែលមកពីភូមិ បែកចានថ្មី និងជាអ្នកមកសំអាតធ្មេញផងនោះ ក៏បានមានប្រសាសន៍ថា "នេះជាការល្អប្រសើរណាស់ ដែលពួកគាត់បានអញ្ជើញមកទីនេះ ក្នុងការបានព្យាបាលយើងខ្ញុំ ទាំងអស់គ្នាដោយមិនគិតថ្លៃ ជាពិសេសពួកគាត់បានបង្ហាញអោយឃើញនូវទឹកចិត្តមនុស្សធម៌ ដោយមិនរើសអើងពូជសាសន៍ រឺជាតិសាសន៍ណាទេ"។ លោកបានបន្តទៀតថា "សម្រាប់អារម្មណ៍របស់ខ្ញុំ ពិតជាសប្បាយរីករាយណាស់ ហើយបំណងរបស់ខ្ញុំ ចង់អោយពួកគាត់មកទីនេះជារៀងរាល់ឆ្នាំ"។ ស្របពេលនោះដែរលោកជោត ប៊ុនធឿន អាយុ២២ឆ្នាំ ក៏បានមានប្រសាសន៍ផងដែរថា "ខ្ញុំចាប់អារម្មណ៍ខ្លាំងណាស់ នៅពេលបានដឹងដំណឹងថា មានក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ធ្វើការព្យាបាលដោយមិនគិតថ្លៃ តាមរយៈមិត្តភក្ត្ររបស់ខ្ញុំ ហើយរូបខ្ញុំផ្ទាល់ក៏យល់ឃើញផងដែរថា នេះជាការចូលរួមចំណែកមួយ ក្នុងផ្នែកនៃសុខភាព ដើម្បីអោយបងប្អូនទាំងអស់បានយល់ដឹងអំពី បញ្ហាមាត់ធ្មេញ"។ លោកបានបន្តទៀតថា "ខ្ញុំមានចិត្ត និងអារម្មណ៍សប្បាយរីករាយណាស់ នៅពេលដែរបានទទួលសេវាដ៏ល្អបែបនេះ ហើយខ្ញុំសង្ឃឹមថា ពួកគាត់នឹងមកកាន់ទីនេះជារៀងរាល់ឆ្នាំ"។ សូមបញ្ជាក់ថាក្រុមគ្រូពេទ្យស្ម័គ្រចិត្ត កាណាដា នេះបានមកព្រះសហគមន៍ នៅក្នុងភូមិភាគបាត់ដំបងជារៀងរាល់ឆ្នាំ។

សន្តី ថេរេសា នៅក្រុង លីស៊ីយ៉ឺ

ក្នុងរតនៈលេខមុន យើងបានស្គាល់ សន្តី ថេរេសា នៅក្រុង លីស៊ី-យ៉ឺ រីឯលេខនេះគឺ យើងបន្តអាននូវប្រវត្តិរបស់សន្តី ថេរេសា បន្តទៀត។ តើថេរេសា បានផុតដង្ហើមនៅវេលាម៉ោងប៉ុន្មានា?តើថេរេសា បានទូលអង្វរអ្វីខ្លះ ទៅព្រះជាម្ចាស់ ។

"អូ!អ្នកម្តាយអើយ! ដ្បិតពែងពេញបរិបូណ៌។ ព្រះជាម្ចាស់មិនដែលលះបង់ចោលខ្ញុំ។ ឪព្រះអង្គអើយ! សូមអាណិតអាសូរ នាងខ្ញុំផង។ នាងខ្ញុំសុខចិត្តធ្វើអ្វីៗ ដែលព្រះអង្គចង់ឲ្យនាងខ្ញុំធ្វើ ប៉ុន្តែសូមអាណិតអាសូរនាងខ្ញុំផង។ ឪបងស្រីទាំងឡាយអើយ! សូមជួយអង្វរព្រះជាម្ចាស់ចំពោះនាងខ្ញុំផង។ នាងខ្ញុំហាក់ដូចជាកូនង៉ា អស់កម្លាំងមែនទែន។ សូមបងស្រីជួយនាងខ្ញុំដើម្បីចេះទទួលមរណៈភាព យ៉ាងសមរ-ម្យ។ អ្វីៗ ដែលនាងខ្ញុំបានសរសេរអំពីទុក្ខលំបាកត្រូវមែន មែនហើយនាងខ្ញុំបានស្តាយ ដោយបានថ្វាយខ្លួនទៅសេចក្តីស្រលាញ់របស់ ព្រះអង្គ។ បន្តិចទៀតថេរេសានិយាយថា៖ "ខ្ញុំមិន ដែលស្មានថាមនុស្សយើងអាចនឹង ឈឺបែបនេះបានទេ។ នាងខ្ញុំយល់ថាការឈឺចាប់នេះមកពីនាងខ្ញុំចង់ទទួលទុក្ខលំបាក ដោយស្រឡាញ់ដើម្បីសង្គ្រោះ បងប្អូនឯទៀត"។ ប្រហែលជាម៉ោង៧:២០ នាទីល្ងាចនាងផុតដង្ហើម។ បន្តិចទៀត ថេរេសា និយាយថាឥលូវមែនមែននាងទើបតែបានអាយុ ២៤ឆ្នាំប៉ុណ្ណោះទេ។ (ចប់)

យើងខ្ញុំសូមអរគុណ ចំពោះបងប្អូនទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃ អាននូវប្រវត្តិរបស់សន្តី ថេរេសា តាំងពីដើមរហូតដល់ចប់។ ក្នុងនោះដែរ ក៏មានសំណួរមួយចំនួន ដើម្បីសាកសួរ ដល់បងប្អូន និងមិត្តអ្នកអាន ចំពោះជីវិតក្នុងការរស់នៅរបស់សន្តី ថេរេសា។ តើថេរេសាជាគំរូចំពោះយើង សព្វថ្ងៃយ៉ាងដូចម្តេច?

១.នាងមានចិត្តស្ទុះស្ទា ចំពោះអ្វីៗដែលនាងចង់បាន ក៏ប៉ុន្តែនាងចេះស្តាប់បង្គាប់ ណែនាំរបស់បងស្រី។
២.ពេល ដែលនាងឈឺធ្ងន់ នាងពឹងផ្អែកទៅលើព្រះជាម្ចាស់ជានិច្ច។

សិក្ខាសាលា អន្តរជំនឿ និងការរួមគ្នាការពារបរិស្ថាន

ដោយៈ មុយ សាម៉ែត

ជាការពិតណាស់ នៅទូទាំងសកលលោក តែងតែមានការការពារបរិស្ថាន និងការតស៊ូមតិចំពោះបរិស្ថានធម្មជាតិ មិនថាជាតិសាសន៍ដូចគ្នា រឺខុសគ្នានោះទេ។

Photo: An Rittyrath

កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០១៣ ព្រះសហគមន៍ កាតូលិក បាត់ដំបង មានសិក្ខាសាលា ដែលស្តីអំពី អន្តរជំនឿ និងការរួមគ្នាការពារបរិស្ថាន។ ក្នុងនោះក៏មានការចូលរួមពីសំណាក់ លោកអភិបាល គីគេ ហ្វីការេដូ និងលោកឪពុកគួតេតដែលជាតំណាងកិត្តិយសក្នុងអង្គសិក្ខាសាលា ព្រមទាំងបងប្អូនដែលមានសាសនាខុសៗ គ្នាដូចជា អ៊ីស្លាមសាសនា គ្រីស្តសាសនា ព្រះពុទ្ធសាសនា និងព្រះវិហារមហាធម៌មេត្រី ប្រមាណ ៥២នាក់។ គោលបំណង នៃសិក្ខាសាលានេះគឺ ការចូលរួមចែករំលែកអំពីជំនឿរវាងសាសនាផ្សេងៗ ដែលប្រៀនប្រដៅទាក់ទងទៅនឹង ការការពារបរិស្ថានធម្មជាតិ ព្រមទាំងការតស៊ូមតិដើម្បីការពារបរិស្ថានធម្មជាតិ។ ជាពិសេសទៅទៀតនោះ នៅក្នុងសិក្ខាសាលានេះគឺ ដើម្បីស្គាល់គ្នា និងឲ្យនេះក៏មានវាគ្មិន ដែលជាតំណាងឲ្យសាសនាខុសៗគ្នាដូចជា លោក សុប ផារឹត ដែលជាវាគ្មិនតំណាងឲ្យអ៊ីស្លាមសាសនា ព្រះតេជគុណ ព្រះមហា វី សុវិជ្ជា តំណាងឲ្យព្រះពុទ្ធសាសនា លោកឪពុក ហ្គាប៊ី និងជាតំណាងវាគ្មិន របស់គ្រីស្ត សាសនា ផងដែរ។ លោក សុប ផារឹត ដែលជាវាគ្មិនក៏មានប្រសាសន៍ ដែលទាក់ទង និងបរិស្ថានតាមសាសនារបស់លោកដែរថា "ព្រះឱលោះបានប្រៀនប្រដៅយើង ឲ្យចេះការពារបរិស្ថានធម្មជាតិ ព្រមទាំងបានប្រៀនប្រដៅយើង ឲ្យចេះការពារជីវិត សត្វ មនុស្ស និងរុក្ខជាតិនានា"។ ខណៈពេលនោះ ព្រះតេជ-

ពិធីទទួលជំហានទី២



Photo:An Rittyrath

ដោយៈ មុយ សាម៉ែត

កាលពីថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៣ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំពិធីទទួលជំហានទី ២ ដល់សិស្ស ដែលបានទទួលការអប់រំជំនឿ។ ពិធីនេះធ្វើឡើងស្របពេល ក្នុងពិធីអភិបូជា ដែលមានលោកអភិបាល គីគេ ហ្វីការេដូ ដែលជាអ្នកទទួលខុសត្រូវនៅក្នុងភូមិភាគបាត់ដំបង និងលោកបូជាចារ្យចំនួន ៧អង្គ ដែលបានរួមគ្នាថ្វាយពិធីអភិបូជា។ ក្នុងនោះ ក៏មានបងប្អូនចំនួន ៧១ នាក់ ដែលត្រៀមនឹង ទទួលជំហានទី២ ដោយមកពីព្រះសហគមន៍ ផ្សេងៗ គ្នាដូចជា ព្រះសហគមន៍ ព្រែកទោល តាហែន ខ្នាចរមាស ស្នឹង ប៉ោយប៉ែត ស្វាយស៊ីសុផុន ទំព្ងង បាត់ដំបង។ លោកអភិបាល គីគេ បានមានប្រសាសន៍ ស្របពេលបកស្រាយព្រះគម្ពីរថា "នេះជារដូវអប់រំពិសេស ដូច្នេះយើងត្រូវចេះប្រើប្រាស់ នូវអ្វីដែលព្រះជាម្ចាស់បានប្រទាន នូវអំណោយទានមកដល់ពួកយើង តើយើងប្រើប្រាស់អំណោយទានរបស់ពួកយើងយ៉ាងដូចម្តេច? គឺអំណោយ ដែលយើងមានត្រូវយកទៅបម្រើអ្នកដទៃ និងដើម្បីខ្លួនឯង ព្រមទាំងក្រុមគ្រួសារ រឺក៏ក្រុមអ្វីផ្សេងៗទៀតដូចជាក្រុមយុវជន"។ លោកអភិបាលបានបន្តទៀតថា "ឥឡូវនេះយើងរាល់គ្នា និងក្លាយជាគ្រីស្តបរិស័ទ តើយើងជាគ្រីស្តបរិស័ទមានតួនាទីអ្វីខ្លះ? គឺយើងត្រូវមានតួនាទីចេះបម្រើអ្នកដទៃ និងចេះថ្វាយបង្គំព្រះជាម្ចាស់ ដែលធ្វើឲ្យខ្លួនយើងបានល្អ នៅពេលដែរយើងបានទទួលជំហានទី២នេះ"។ ក្នុងនោះប្អូនស្រី រិត ស្រីចេង អាយុ១៥ ឆ្នាំ មកពីព្រះសហគមន៍ តាហែន ដែលជាអ្នកទទួលជំហានទី២ បានមានប្រសាសន៍ថា "ខ្ញុំបានសិក្សា និងទទួលការអប់រំជំនឿ អស់រយៈពេលបីឆ្នាំមកហើយ ក្នុងនោះនៅពេល ដែលខ្ញុំបានសិក្សា និងទទួលការអប់រំជំនឿ ខ្ញុំមានការផ្លាស់ប្តូរជាច្រើនដូចជា ធ្វើឲ្យខ្ញុំចេះជួយអ្នកដទៃ និងចេះអធិដ្ឋានច្រើនព្រមទាំងចេះស្តាប់ព្រះបន្ទូល និងមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ រឺក្រុមគ្រួសាររបស់នាងខ្ញុំ"។ ស្របពេលនោះដែរលោក សុវណ្ណ អាយុ២៥ ឆ្នាំ មកពីព្រះសហគមន៍ ស្វាយស៊ីសុផុន ដែលជាអ្នកទទួលជំហានទី ២ ផងដែរនោះ ក៏មានប្រសាសន៍ថា "ខ្ញុំបានសិក្សា និងទទួលការអប់រំជំនឿពីលោកគ្រូ អ្នកគ្រូ អស់រយៈពេលបីឆ្នាំ ហើយនៅក្នុងរយៈពេលដែលខ្ញុំបានសិក្សានេះ ពិតជាធ្វើឲ្យខ្ញុំមានការផ្លាស់ប្តូរ ជាពិសេសគឺធ្វើឲ្យជំនឿរបស់ខ្ញុំកាន់តែរឹងមាំ និងចែករំលែកនូវបទពិសោធន៍ថ្មីៗ។

Photo: An Rittyrath

កម្មវិធីសម្ពោធមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈកសិកម្ម ដុនបូស្កូ បាត់ដំបង ដែលស្ថិតនៅភូមិសាសាបាឡាត់ ក្រុងបាត់ដំបង ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់លោកអភិបាល គីគេ ហ្វីការេដូ ជាអភិបាលរបស់ព្រះសហគមន៍ កាតូលិកភូមិភាគបាត់ដំបង កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣។ ក្នុងនោះក៏មានការចូលរួមពីសំណាក់ម្ចាស់ជំនួយ អាឡឺម៉ង់ និងហូឡង់។

Photo: Tom Chea

ពាន់រង្វាន់ កាតូលិក ឆាលដ្រេន ហ្វុតបល់ លិក
(Catholic Children Football League)
ដែលមានឈ្មោះកាត់ថា ស៊ី ស៊ី អិហ្វ អិល (CCFL) បានបើកការប្រកួតហើយ កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយមានការអញ្ជើញចូលរួមក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់លោកអភិបាល គីគេ ហ្វីការេដូ ក្នុងការបើកកម្មវិធីនេះ។

សិក្ខាសាលាស្តីពី តាពជាអ្នកណែនាំ

Photo: Mov Samet

មណ្ឌលប៉ាស្ទ័រ៉ាល់ អូស្ការ រ៉ូមេរ៉ូ កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ នៅព្រះសហគមន៍ កាតូលិកបាត់ដំបង បានរៀបចំសិក្ខាសាលាមួយ ដែលស្តីអំពី តាពជាអ្នកណែនាំ ដោយមានការចូលរួមពីសំណាក់លោកឪពុក បងប្រុស បងស្រី ព្រមទាំងបុគ្គលិកប្រមាណ ៤០ នាក់។ សិក្ខាសាលានេះគឺមានគោលបំណងចង់បង្ហាញ ទៅដល់បុគ្គលិកទាំងអស់ ត្រូវមានទំនាក់ទំនងគ្នា និងចេះធ្វើការរួមគ្នាដោយពឹងផ្អែកគ្នាទៅវិញទៅមក។ ក្នុងនោះលោកឪពុក ជោជោ ម៉ាហ្គាឌៀ ដែលជាវាគ្មិន និងជាប្រធានធំនៃក្រុមគ្រួសារសហជីវិនព្រះ យេស៊ូ ប្រចាំនៅប្រទេស ហ្វីលីពិន បានធ្វើ បទបង្ហាញ ដែលទាក់ទងនឹង តាព ហើយ ជាអ្នកដឹកនាំ ព្រមទាំងមានការចូលរួមសម្របសម្រួលពីសំណាក់លោក ឪពុក តូតេតផងដែរ។ សូមបញ្ជាក់ថា កាលពីថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០១១ កន្លងទៅលោកឪពុក ជោ-ម៉ាហ្គាឌៀ ក៏ធ្លាប់បានមករួចមកបង្រៀនដល់អ្នកណែនាំរបស់យើងនៅក្នុងព្រះសហគមន៍បាត់ដំបងដែលស្តីពីការប្រៀនប្រដៅរបស់សម្តេចប៉ាប ក្នុងការបង្ហាញសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណា។ ដោយ:មុយ សាម៉ែត

Photo: An Rittyrath

បងស្រី ថេរេស៊ីតា បានអញ្ជើញមកព្រះសហគមន៍ កាតូលិកបាត់ដំបង នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយមានកិច្ចស្វាគមន៍ ពីសំណាក់លោកឪពុក តូតេ បងប្រុស បងស្រី ព្រមទាំងយុវជន និងបងប្អូនគ្រីស្តបរិស័ទជាច្រើននាក់ទៀត។ បងស្រី គឺជាប្រធានមណ្ឌល សាលីស៊ាន និងជាប្រធានផ្នែកអប់រំជំនឿ។ បងស្រីក៏បានសួរសុខទុក្ខបងប្អូននៅទីនេះផងដែរ។

ធម្មយាត្រា សប្តាហ៍សុខដុមរមនាអន្តរសាសនាពិភពលោក

Photo: An Rittyrath

កាលពីថ្ងៃទី៦-៧ ខែកុម្ភៈ ឆ្នាំ២០១៣ ព្រះសហគមន៍ កាតូលិកបាត់ដំបង បានចូលរួមនៅធម្មយាត្រាដើម្បី សប្តាហ៍សុខដុមរមនាអន្តរសាសនាពិភពលោក នៅរមណីយដ្ឋាន ភ្នំប្រាំពីរ ដែលស្ថិតនៅក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ កម្មវិធីនេះមានការចូលរួមពីបណ្តាលសាសនាបីធំៗដូចជា គ្រិស្តសាសនា ព្រះពុទ្ធសាសនា និងអ៊ីស្លាមសាសនា ប្រមាណ១០០នាក់។ គោលបំណងនៃធម្មយាត្រានេះគឺ អបអរសាទរទិវា សន្តិភាពពិភពលោក ដើម្បីការពារបរិស្ថាន ដែលជាកន្លែងរបស់ពួកយើងរស់នៅ និងសត្វរុក្ខជាតិ ទាំងឡាយដែលប្រកបដោយភាពសុខដុមរមនា។ ជាពិសេស គោលបំណងមួយទៀតនោះ ដើម្បីអបអរសាទរ អង្គការសហប្រជាជាតិ ដែលបានបង្កើតទិវាសន្តិភាពរវាងសាសនា និងសាសនា។ នៅក្នុងកម្មវិធីនេះក៏បានប្រារព្ធនូវពិធីឧទ្ទិសកុសលជូនដល់ព្រះវិញ្ញាណក្ខន្ធ ព្រះបាទនរោត្តម សីហនុ ផងដែរ។ កម្មវិធីធម្មយាត្រានេះ ក៏មានការដាំកូនឈើជាច្រើនដើម រួមគ្នារវាងសាសនាទាំងបីព្រមទាំងការបញ្ចេញយោបលរបស់អ្នកណែនាំ តាមសាសនានីមួយៗ បន្ទាប់ពីការដាំកូនឈើរួចហើយ។

ដោយ:មុយ សាម៉ែត